# ថ្នាំចាក់បង្ការរោគអុតធំ

## តើការអ្វីខ្លះដែលអ្នកត្រូវដឹង

## 1 តើរោគអុតធំ ជាអ្វី?

**រោគអុតធំជាជំងឺសាហាវមួយដែលអាចសម្លាប់ដល់ទៅ 30 ភាគរយនៃមនុស្សដែលកើតជំងឺនេះ។**

វាកើតឡើងដោយមេរោគមួយឈ្មោះវ៉ារីអូឡា **(variola)** ដែលអាចចម្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ តាមរយៈការនៅជិតស្និទ្ធគ្នា។

រោគអុតធំក៏អាចបណ្តាលឲ្យមាន :

- កន្ទួលខ្លាំងលើស្បែកដែលអាចបន្សល់ស្នាមពេលណាបានជាហើយ
- គ្រុនក្តៅខ្លាំង
- អស់កម្លាំង
- ឈឺក្បាលយ៉ាងខ្លាំង និងឈឺខ្នង
- ខ្វាក់ភ្នែក

សំណុំរឿងចុងក្រោយនៃជំងឺអុតធំដែលកើតនៅក្នុងពិភពលោកនេះ ដោយសារធម្មជាតិ គឺនៅឆ្នាំ 1977។

## 2 តើហេតុអ្វីបានជាត្រូវការចាក់ថ្នាំបង្ការ?

ថ្នាំចាក់បង្ការរោគអុតធំ អាចការពារមនុស្សធ្វើការជាមួយអ្នកដែលកើតរោគអុតធំ ឬមេរោគប្រហែលគ្នាផ្សេងទៀតនៅក្នុងមន្ទីរពិសោធន៍។

គេជឿថា ពួកក្រុមភេរវជនឬរដ្ឋាភិបាល ដែលជាសត្រូវនឹងសហរដ្ឋអាមេរិកអាចមានមេរោគអុតធំ ហើយនឹងប្រើវាធ្វើជាអាវុធសង្គ្រាមគីមី។ ថ្នាំចាក់បង្ការរោគអុតធំ អាចការពារក្រុមបុគ្គលិកពេទ្យដែលឆ្លើយតបនឹងភាពអាសន្ន និងអ្នកដែលឆ្លើយតបជាដំបូងជាមួយរោគអុតធំ។ ក្រុមទាំងនេះនឹងសំគាល់ថាតើមនុស្សណាខ្លះដែលត្រូវការចាក់ថ្នាំបង្ការ ដើម្បីទប់កុំឲ្យមានកើតជំងឺ និងរៀបចំមន្ទីរចាក់ថ្នាំ ការពារសាធារណៈ។

ក្នុងករណីមានកើតជំងឺ ឬមានភាពអាសន្ន នោះការចាក់ថ្នាំបង្ការរោគអុតធំ អាចការពារមនុស្សមិនឲ្យឆ្លងមេរោគអុតធំ។

## 3 ថ្នាំចាក់បង្ការរោគអុតធំ

ថ្នាំចាក់បង្ការរោគអុតធំ គឺធ្វើមកពីមេរោគមួយឈ្មោះវ៉ាស៊ីនញ៉ា **(vaccinia)**។ មេរោគ **vaccinia** មានលក្ខណៈស្រដៀងនឹងមេរោគអុតធំ តែមានគ្រោះថ្នាក់តិចជាង។ ថ្នាំចាក់បង្ការរោគ vaccinia អាចការពារមនុស្សកុំឲ្យកើតរោគអុតធំ។ ថ្នាំនេះមិនមានមេរោគអុតធំឡើយ។

ការថ្នាំចាក់នៅពេល មុន*មានកើតមេរោគនេះ អាចនឹងការពារមនុស្សជាច្រើន*ពីអុតធំ។ ថ្នាំចាក់បង្ការរោគក្នុងរយៈពេល 3 ថ្ងៃ*បន្ទាប់ពីឆ្លងរោគមក* អាចការពារជំងឺ ឬក៏អាចធ្វើឲ្យជំងឺមានភាពស្រាល។ ពិធីការពារនៃការចម្លងរោគអាចមានប្រសិទ្ធិភាពពី 3 ទៅ 5 ឆ្នាំ និងអាចការពារពីជំងឺធ្ងន់ធ្ងរ និងការស្លាប់ផង ដែលអាចមានប្រសិទ្ធិភាពបាន 10 ឆ្នាំ ឬច្រើនទៀត។

## 4 តើអ្នកណាខ្លះអាចទទួលថ្នាំចាក់ បង្ការរោគអុតធំ និងនៅពេលណា?

### ការប្រើតាមធម្មតា នៅពេលគ្មានភាពអាសន្ន (មិនកើតជំងឺ)

- បុគ្គលិកធ្វើការជាប់ទាក់ទងនឹងការចិញ្ចឹមមេរោគ ឬសត្វដែលមានរោគ ឬដែលចម្លងដោយមេរោគ vaccinia ឬដោយមេរោគដែលមានភាពស្រដៀងគ្នាផ្សេងៗ (ដូចជា អុតស្វា អុតគោ ឬអុតចំបង)។
- សាធារណៈសុខាភិបាល មន្ទីរពេទ្យ និងបុគ្គលិកផ្សេងៗទៀត ដែលតាមធម្មតាជាអ្នកមានអាយុរវាង 18 និង 65 ឆ្នាំ ជាអ្នកដែលឆ្លើយតបទៅនឹងករណីនៃជំងឺអុតធំណាមួយ ឬនៅពេលមានកើតជំងឺអុតធំ។

### ការប្រើនៅពេលមានភាពអាសន្ន (ជំងឺអុតធំកើត)

- អ្នកណាដែលនៅ*ជាប់ផ្ទាល់ជាមួយ*មេរោគអុតធំ គប្បីតែចាក់ថ្នាំការពារមួយម្តងជាបន្ទាន់ បន្ទាប់ពីបានដឹងភ្លាម។
- អ្នកណាដែល *ប្រឈមទល់នឹង* មេរោគអុតធំ អាចត្រូវការចាក់ថ្នាំការពារនៅពេលបិតក្នុងសភាពគ្រោះថ្នាក់នឹងកើត ឬនៅពេលដឹងភ្លាម។

*មនុស្សដែលបានចាក់ថ្នាំរួចហើយ អាចចាក់សាជាថ្មីទៀតបានបន្ទាប់ពី 3 ទៅ 10 ឆ្នាំ ស្រេចទៅលើសណ្ឋាននៃភាពគ្រោះថ្នាក់។*

## 5 បន្ទាប់ពីការចាក់ថ្នាំ

សូមមើលសន្លឹកបន្ថែម VIS ផ្នែក A និង B សំរាប់ព័ត៌មានបន្ថែម

### ដឹងថា ប្រតិកម្មនឹងកើតមាន

វានឹងមានការពងសាច់នៅកន្លែងចាក់ថ្នាំ។ ក្រោយមកវានឹងក្លាយទៅជាក្រមរ។ នៅទីបញ្ចប់ ក្រមរនឹងរុះ ដោយបន្សល់ទុកនូវស្នាម។

អ្នកនឹងដឹងថាមានការហើម ការឈឺប៉ះសឹងមិនបាន នៅកន្លែងដុំរឹងនោះ ដែលអាចមានរយៈពេលពី 2 ទៅ 4 អាទិត្យ ក្រោយដែលដុំរឹងបានជា។ ក៏មានការរមាស់នៅជុំវិញកន្លែងចាក់ អស់កំឡាំង គ្រុន ឈឺក្បាល ឬឈឺសាច់ដុំផង។

### ការថែរក្សាកន្លែងចាក់ថ្នាំ

**បន្ទាប់ពីក្រមររុះ អ្នកអាចចំឡងមេរោគ vaccinia ទៅមនុស្សផ្សេងទៀត ឬទៅផ្នែកដទៃទៀតនៃរូបកាយរបស់អ្នក។**

ដើម្បីការពារ អ្នកត្រូវគ្របកន្លែងចាក់ថ្នាំដោយប្រើបង់រុំរបួសស្តើងៗ ។ (នៅពេលធ្វើការ បុគ្គលិកសុខាភិបាលនឹងត្រូវការពារបន្ថែមទៀត ដូចជាប្រើបង់រុំរបួសបានរាំងរាបមេរោគ នៅពីលើបង់រុំរបួសនេះទៀត)។

ត្រូវផ្លាស់ប្តូរបង់រុំរបួសនេះតាមសេចក្តីត្រូវការ (ពី 1-3 ថ្ងៃ បើសិនជាប្រើបង់

បន្តទៅទំព័របន្ទាប់...

រុំរបួសស្តើងៗ ហើយពី 3-5 ថ្ងៃ សំរាប់បង់រុំរបួសបានរំងាប់មេរោគ)។ ត្រូវគ្របកន្លែងចាក់ថ្នាំ ដោយបង់រុំរបួសដែលទឹកពុំអាចចូលបាន។ កុំប៉ះកន្លែងចាក់ថ្នាំ ហើយទៅប៉ះកន្លែងណាមួយទៀតនៅលើរូបកាយរបស់អ្នក ដោយមិនបានលាងដៃជាមុន។ កុំអេះ ឬលាបព្រេងនៅកន្លែងចាក់ថ្នាំ ។ ក៏កុំប៉ះភ្នែកអ្នក ឬផ្នែកនៃរាងកាយរបស់អ្នក បន្ទាប់ពីប្តូរបង់រុំរបួស ឬបានប៉ះកន្លែងចាក់ថ្នាំ។

ពាក់អាវដែលគ្របជិតកន្លែងចាក់ថ្នាំ សំរាប់ជាការការពារបន្ថែម ជាពិសេសក្នុងករណីដែលមានការជាប់ទាក់ទងនឹងការនៅជិតដិតគ្នា (ដូចជា ឪពុកម្តាយនៃកូនក្មេងតូចៗ )។

ដាក់បង់រុំរបួសចាស់ក្នុងថង់ផ្លាស់ទិក និងបិទឲ្យជិត រួចបោះវាចោល។ ក៏ត្រូវធ្វើដូចគ្នាដែរ ចំពោះកមក្រមរដែលរុះ។ កុំប្រើក្រម៉ាចូលគ្នា។ ត្រូវបោកសំភារៈដែលប៉ះកន្លែងចាក់ថ្នាំ។ លាងដៃរបស់អ្នកបន្ទាប់ពីបានប៉ះ កន្លែងចាក់ថ្នាំ បង់រុំរបួស ខោអាវ ក្រណាត់ក្រាល ឬកន្សែង ដែលបានប៉ះកន្លែងចាក់ថ្នាំ។

**កន្លែងចាក់ថ្នាំគួរតែពិនិត្យមើលប្រហែលជា 7 ថ្ងៃ បន្ទាប់ពីចាក់ថ្នាំរួច ដើម្បីឲ្យដឹងប្រាកដថាការចាក់ថ្នាំមានប្រសិទ្ធិភាព។**

## 6 មនុស្សខ្លះមិនគួរចាក់ថ្នាំបង្ការរោគអុតធំ ឬគួររង់ចាំឡើយ

*សូមមើលសន្លឹកបន្ថែម VIS ផ្នែក C, D និង E សំរាប់ពត៌មានបន្ថែម*

### ពេលធម្មតា គ្មានភាពអាសន្ន (មិនកើតជំងឺ)

- អ្នកណាដែលមានរោគត្រអក ឬរមាស់រលោកស្បែកខ្លាំង ឬធ្លាប់មានប្រវត្តិកើតរោគណាមួយខាងលើ មិនត្រូវទទួលថ្នាំចាក់បង្ការរោគអុតធំទេ។
- អ្នកណាដែលមានជំងឺស្បែក *ដែលអាចជ្រាបចូលក្នុងស្បែក* (ដូចជាធ្វើឲ្យឡើងកន្ទួល រលោកស្បែកធ្ងន់ធ្ងរ  កញ្ជ្រិល ជំងឺរលោកស្បែក អុតស្វាយ អុតជួរ ឬមានមុនមុខខ្លាំង) គួរតែរង់ចាំទាល់តែបានគ្រាន់បើសិន មុននឹងចាប់ផ្តើមចាក់ថ្នាំបង្ការរោគអុតធំ។
- អ្នកណាដែលមានប្រព័ន្ធការពារជំងឺក្នុងខ្លួនខ្សោយ មិនអាចចាក់ថ្នាំបង្ការអុតធំបានទេ គិតរួមទាំងអ្នក :
  - ដែលមានមេរោគ HIV/AIDS ឬមេរោគផ្សេងទៀតដែលជាប់ទាក់ទងនឹងប្រព័ន្ធការពារជំងឺ។
  - ដែលមានប្រព័ន្ធការពារជំងឺខាងក្នុង ត្រូវបានបំផ្លាញដោយមេរោគបំផ្លាញប្រព័ន្ធការពារជំងឺ ដូចជារោគរលាកភ្លាសស្បែកជាដើម។
  - ដែលកំពុងព្យាបាល ឬបានព្យាបាលដោយថ្នាំដែលជាប់ទាក់ទងនឹងប្រព័ន្ធការពារជំងឺ ដូចជាថ្នាំស្តេរ៉យ ឬថ្នាំខ្លះដែលព្យាបាលប្រព័ន្ធការពារជំងឺ ឬថ្នាំដែលមានទំនាក់ទំនងជាមួយសរីរាង្គ ឬការផ្សាំចិញ្ចើមឆ្អឹង។
  - អ្នកមានរោគមហារីកឈាម រោគសាច់ដុះក្នុងជាលិកាទឹករងៃ ឬរោគមហារីកផ្សេងៗទៀត។
  - ដែលកំពុងព្យាបាលជំងឺមហារីក ដោយរស្មីអិក្ស ឬដោយថ្នាំព្យាបាលក្នុងពេល 3 ខែចុងក្រោយ។
- ស្ត្រីមានផ្ទៃពោះមិនត្រូវចាក់ថ្នាំបង្ការរោគអុតធំទេ។
- ស្ត្រីគួរតែជៀសវាងកុំឲ្យមានទំងន់ 4 អាទិត្យ ក្រោយពេលចាក់ថ្នាំបង្ការរោគអុតធំរួច។

*បុគ្គលណាដែលរស់នៅជាមួយ ឬមានការជិតដិតនឹងរូបកាយ ជាមួយនឹងជនដែលឋិតក្នុងលក្ខណៈខាងលើ មិនគួរចាក់ថ្នាំការពាររោគអុតធំឡើយ ពីព្រោះភាពគ្រោះថ្នាក់បណ្តាលមកពីការនៅជិតដិតគ្នា។ (ការនៅជិតដិត គឺគិតទាំងមនុស្សដែលរស់នៅក្នុងផ្ទះ និងអ្នកដែលបានប៉ះពាល់រាងកាយ ដូចជាអ្នករួមដំណេកនឹងគ្នា តែមិនរាប់មិត្តភ័ក្តិ ឬអ្នកធ្វើការជាមួយទេ)។*

- ថ្នាំចាក់បង្ការរោគអុតធំ មិនដំរូវសំរាប់អ្នកណាដែលមានអាយុតិចជាង 18 ឆ្នាំទេ។
- កុំចាក់ចាក់ថ្នាំបង្ការរោគអុតធំ បើអ្នកធ្លាប់មានប្រតិកម្មយ៉ាងធ្ងន់ធ្ងរ ដែលគំរាមកំហែងដល់អាយុជីវិត ចំពោះជាតិថ្នាំ **polymyxin B, streptomycin, chlortetraccycline, neomycin** ឬធ្លាប់មានប្រតិម្មចំពោះថ្នាំចាក់បង្ការរោគអុតធំពីមុន។
- ម្តាយដែលបំបៅកូន មិនត្រូវទទួលថ្នាំចាក់បង្ការរោគអុតធំឡើយ។
- មនុស្សណាដែលប្រើថ្នាំដាក់ភ្នែកសំរាប់រំងាប់មេរោគ មិនត្រូវចាក់ថ្នាំបង្ការរោគអុតធំទេ។
- មនុស្សណាដែលឈឺល្មម ឬឈឺខ្លាំងនៅពេលត្រូវចាក់ថ្នាំ នោះតាមធម្មតាគួរតែរង់ចាំទាល់តែបានគ្រាន់បើឡើងវិញ មុននឹងទទួលថ្នាំចាក់បង្ការរោគអុតធំ។

> បើអ្នកមានសំណួរផ្សេងៗ ចំពោះលក្ខណៈដែលបានរៀបរាប់ខាងលើ សូមសួរយោបល់ដល់អ្នកផ្តល់ការថែរក្សាសុខភាពរបស់អ្នក មុននឹងទទួលថ្នាំចាក់បង្ការរោគអុតធំ។

### ការប្រើនៅពេលមានភាពអាសន្ន (រោគអុតធំកើត)

- ការហាមឃាត់ទាំងនេះ ប្រហែលជាមិនយកមកអនុវត្ត នៅក្នុងករណីមានកើតរោគអុតធំទេ។

## 7 តើគ្រោះមានថ្នាក់អ្វីខ្លះ ដែលបណ្តាលមកពីថ្នាំចាក់បង្ការរោគអុតធំ?

*សូមមើលសន្លឹកបន្ថែម VIS សំរាប់ពត៌មានបន្ថែម*

ដំណឹងខាងក្រោមនេះប្រាប់អំពីប្រតិកម្មផ្សេងៗដែលបានដឹង ចំពោះថ្នាំចាក់បង្ការរោគអុតធំ។ ថ្នាំចាក់បង្ការរោគមួយ ក៏ដូចជាថ្នាំផ្សេងទៀតដែរ ដ្បិតវាអាចមានផលវិបាកធំៗ គឺគិតទាំងអ្វីៗដែលមិនទាន់ដឹងពីវានៅឡើយ ក៏ដូចជាការមាន ប្រតិកម្មផ្សេងៗ។ ភាពគ្រោះថ្នាក់នៃថ្នាំចាក់បង្ការរោគអុតធំ ដែលបណ្តាលឲ្យ មានគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬដល់ស្លាប់ នោះមានតិចណាស់ ។

### បញ្ហាតិចទៅមធ្យម

- កន្ទួលតិចៗ អាចមានរយៈពេលពី 2-4 ថ្ងៃ។
- គ្រុនក្តៅលើសពី 100 អង្សាហ្វារិនហាយ (ប្រហែល 10% នៃមនុស្សចាស់)
- ដុំរុំងនៅកន្លែងផ្សេងទៀតលើរូបកាយ (ប្រហែលមាន 1 ក្នុង 1,900)

*ប្រហែលជា 1 ភាគ 3 នៃមនុស្សដែលទទួលថ្នាំចាក់បង្ការរោគ គិតថាខ្លួនឈឺល្មមដែលមិនចង់ទៅធ្វើការ ឬទៅសាលា ឬផ្លាស់ប្រែសកម្មភាពនានាដែលខ្លួនចង់ធ្វើ ឬអាចសំរាន្តមិនលក់មួយរយៈ។*

បន្តទៅទំព័របន្ទាប់...

## បញ្ហាមធ្យម ទៅដល់ធ្ងន់ធ្ងរ (ដែលត្រូវការថែទាំជាបន្ទាន់)

- ការរលាកភ្នែកដោយព្រោះការរាលដាលរបស់មេរោគ នៃថ្នាំចាក់បង្ការរោគចូលទៅក្នុងភ្នែក អាចធ្វើឲ្យបាត់បង់ចក្ខុវិស័យ។
- កន្ទួលពេញលើរូបកាយ (មានយ៉ាងច្រើន 1 ក្នុង 4,000) ដែលតាមធម្មតាត្រូវបាត់ទៅវិញដោយគ្មានបញ្ហាអ្វីទេ។

## បញ្ហាដែលអាចគ្រោះថ្នាក់ដល់ជីវិត

- កន្ទួលស្បែកខ្លាំង សំរាប់មនុស្សដែលមានរោគត្រអក ឬរោគរមាស់រលាកស្បែកខ្លាំង (មានយ៉ាងច្រើន 1 ក្នុង 26,000 នាក់) អាចកើតមានស្លាកស្នាមខ្លាំង ឬបណ្តាលឲ្យស្លាប់។
- រោគរលាកខួរក្បាល (ការប្រតិកម្មខ្លាំងដល់ខួរក្បាល) (មានយ៉ាងច្រើន 1 ក្នុង 83,000) អាចបណ្តាលឲ្យរលាកខួរក្បាលខ្លាំង ឬអាចស្លាប់បាន។
- ការចាប់ផ្តើមរលាកមុនដំបូង គឺនៅកន្លែងចាក់ថ្នាំ (មានយ៉ាងច្រើន 1 ក្នុង 667,000 ភាគច្រើនគឺមនុស្សដែលមានកំសោយភាពស៊ាំនឹងមេរោគវីរុស) អាចកើតមានស្លាកស្នាមខ្លាំង ឬបណ្តាលឲ្យស្លាប់។

**សំរាប់មនុស្សមួយលាននាក់ដែលចាក់ថ្នាំកាលពីដើម មានរវាង 14 និង 52 នាក់ ដែលមានប្រតិកម្មខ្លាំងគ្រោះថ្នាក់ដល់ជីវិតនៅពេលចាក់ថ្នាំបង្ការរោគអុតធំ ហើយមាន 1-2 នាក់ បានស្លាប់ ។**

*មនុស្សដែលមកប៉ះកន្លែងចាក់ថ្នាំ នៃអ្នកដែលបានចាក់ថ្នាំរួចហើយ ឬជាមួយសំភារៈដែលបានប៉ះពាល់នៅទីនោះ អាចបណ្តាលឲ្យមានប្រតិកម្ម បើសិនជាវាបានចម្លងមេរោគថ្នាំចាក់បង្ការរោគនោះ។*

## 8 | ចុះបើសិនជាមានប្រតិកម្មបង្គួរ ឬប្រតិកម្មខ្លាំង?

*សូមមើលសន្លឹកបន្ថែម VIS ផ្នែក A និង B សំរាប់ពត៌មានបន្ថែម*

### រកមើល :

- កន្លែងចាក់ថ្នាំដែលមើលទៅមិនជាសះល្អតាមលក្ខណៈធម្មតា, កន្ទួល ឬឈឺនៅផ្នែកណាមួយនៃរូបកាយរបស់អ្នក, មានរលាកភ្នែក, ឈឺក្បាលមិនឈប់ ឬគ្រុនក្តៅ, ភាន់ភាំង, ប្រកាច់, ចេះតែងុយដេក, ឬបញ្ហាណាមួយកើតឡើងដោយគ្មានហេតុ។ សញ្ញានៃប្រតិកម្មខ្លាំជាមួយថ្នាំ គិតទាំងការពិបាកដកដង្ហើម, ស្អកក, ដកដង្ហើមញាប់, ផ្តុតស្បែក, ស្លេកស្លាំង, ខ្សោយកំឡាំង, បេះដូងដើរញាប់ ឬវិលមុខ ដែលកើតឡើងពីរបីនាទីទៅ ពីរបីម៉ោងក្រោយពីចាក់ថ្នាំរួច។

### បើសិនជាអ្នកមានបានប៉ះពាល់រូបកាយ ហើយមានការពិសោធន៍ករណីខាងលើ ឬបើសិនជាអ្នកមានការបារម្ភអំពីលក្ខណៈណាមួយដែលអ្នកមានបន្ទាប់ពីចាក់ថ្នាំរួច :

- ទូរស័ព្ទទៅអ្នកផ្តល់ការថែរក្សាសុខភាព ឬយកគាត់ទៅព្យាបាលសុខភាពជាបន្ទាន់។
- ប្រាប់អ្នកផ្តល់ការថែរក្សាសុខភាព ថាអ្នកបានចាក់ថ្នាំបង្ការរោគអុតធំ និងប្រាប់ពេលវេលាដែលបានចាក់។
- ស្នើវេជ្ជបណ្ឌិតរបស់អ្នក ឬពេទ្យរបស់អ្នក ឲ្យគាត់បំពេញឯកសារចាក់ថ្នាំ ឬ (VAERS form) ហើយទាក់ទងនឹងក្រសួងសុខាភិបាល។ អ្នកក៏អាចរាយការណ៍ដោយខ្លួនឯង តាមរយៈអន្តរបណ្តាញរបស់ VAERS នៅ http:www.vaers.org ឬទូរស័ព្ទទៅលេខ 1-800-822-7967 ។

### ការព្យាបាល ចំពោះប្រតិកម្មធ្ងន់ធ្ងរ

- Vaccinia Immune Globulin (VIG)
  អាចជួយមនុស្សដែលមាន ប្រតិកម្មខ្លាំងណាមួយទៅថ្នាំចាក់បង្ការរោគអុតធំ។ រីឯថ្នាំទី 2 ឈ្មោះ
  cidofovir អាចជួយក្នុងករណីខ្លះ។ មិនមានថ្នាំណាមួយក្នុងពេលនេះ ទទួលអនុញ្ញាត្តឲ្យប្រើសំរាប់ករណីនេះឡើយ ហើយវាក៏អាចមានឥទ្ធិពលប្រទូស្តប្រទាំងរបស់វាដែរ ។

### ដំឡៃនៃការព្យាបាល ចំពោះប្រតិកម្មនៃថ្នាំចាក់បង្ការរោគ

- ការព្យាបាលចំពោះប្រតិកម្មខ្លាំង អាចអស់លុយច្រើន។ កម្មវិធីសងប្រាក់ ឲ្យកម្មករព្រោះមានថ្នាក់នៅកន្លែងធ្វើការ ឬការធានារ៉ាប់រងសុខភាព ប្រហែលមិនបង់ថ្លៃទាំងអស់នេះទេ។

- គ្មានកម្មវិធីរបស់រដ្ឋាភិបាលកណ្តាល ដែលចេញលុយឲ្យសំរាប់ការមិនទៅធ្វើការ ឬដោយឈឺពីព្រោះមានជំងឺកើតមកពីការចាក់ថ្នាំ ឬការបារម្ភអំពីការឆ្លងមេរោគទៅអ្នកដទៃ។ ក្រុមហ៊ុន (ថៅកែ)របស់អ្នក អាចប្រាប់ថាបើសិនជាគេ ឬកម្មវិធីសងប្រាក់ឲ្យកម្មករព្រោះមានថ្នាក់នៅកន្លែងធ្វើការ នឹងចេញលុយឲ្យសំរាប់ចំណាយទាំងនេះ។

## 9 | តើខ្ញុំអាចរៀនបន្ថែមទៀតយ៉ាងណាខ្លះ?

- អានសន្លឹកបន្ថែម VIS
- សួរវេជ្ជបណ្ឌិតរបស់អ្នក ឬពេទ្យរបស់អ្នក។ ពួកគាត់អាចបង្ហាញអ្នកនូវកញ្ចប់ពត៌មានពីការចាក់ថ្នាំបង្ការរោគ ឬផ្តល់ពត៌មានផ្សេងៗទៀតបាន។
- ទូរស័ព្ទទៅក្រសួងសុខាភិបាលនៅក្នុងតំបន់ ឬរដ្ឋ ដែលអ្នករស់នៅ ។
- ទាក់ទងទៅក្រសួង មជ្ឈមណ្ឌលសំរាប់ទប់ទល់ និងវិធីការពារជំងឺ (CDC):
  -ហៅលេខ **1-888-246-2675** (ភាសាអង់គ្លេស)
  -ហៅលេខ **1-888-246-2857** (ភាសាអេស្ប៉ាញ៉ុល)
  -ហៅលេខ **1-866-874-2646** (អ្នកពិការត្រចៀក)
  -មើលអន្តរបណ្តាញរបស់រោគអុតធំ នៅ
  http://www.cdc.gov/smallpox

**U.S. Department of Health & Human Services**
ក្រសួង មជ្ឈមណ្ឌលសំរាប់ទប់ទល់ និង វិធីការពារជំងឺ
កម្មវិធីចាក់ថ្នាំការពារជាតិ

Smallpox (1/16/03)    Vaccine Information Statement